Khmer | ភាសាខ្មែរ

# ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាសម្រាប់ឆ្នាំ 2027



ថ្នាក់មូលដ្ឋាន (ត្រូវបានគេស្គាល់ផងដែរថាថ្នាក់ត្រៀម) គឺជាឆ្នាំដំបូងនៃសាលាបឋមសិក្សាក្នុងរដ្ឋវិចថូរៀ។

កូនរបស់អ្នកអាចចាប់ផ្តើមចូលរៀនបាន ប្រសិនបើពួកគេមានអាយុ 5 ឆ្នាំមុនថ្ងៃទី 30 ខែមេសា ឆ្នាំ 2027។ ការចូលរៀនគឺជាកាតព្វកិច្ចខានមិនបាន នៅពេលកូនរបស់អ្នកចូលអាយុ 6 ឆ្នាំ។

## តើខ្ញុំអាចដាក់ពាក្យនៅពេលណា?

ពាក្យសុំចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សារដ្ឋក្នុងរដ្ឋវិចថូរៀសម្រាប់ឆ្នាំ 2027៖

- បើកចាប់ពី**ថ្ងៃចន្ទ ទី 20 ខែមេសា ឆ្នាំ 2026**
- ដល់ពេលកំណត់ត្រឹម**ថ្ងៃសុក្រ ទី 31 ខែកក្កដា ឆ្នាំ 2026។**

## តើសិទ្ធិចុះឈ្មោះចូលរៀនរបស់កូនខ្ញុំមានអ្វីខ្លះ?

នៅក្នុងរដ្ឋវិចថូរៀ កូនរបស់អ្នកមានសិទ្ធិចូលរៀននៅសាលាជិតខាងដែលបានកំណត់របស់ពួកគេ ('សាលារៀនក្នុងតំបន់' របស់អ្នក) នៅក្រោម *ច្បាប់កំណែទម្រង់ការអប់រំ និងការបណ្តុះបណ្តាល ឆ្នាំ 2006*។ សាលាក្នុងតំបន់របស់អ្នកត្រូវបានកំណត់ដោយតំបន់សាលារៀនសម្រាប់អាសយដ្ឋានអចិន្ត្រៃយ៍របស់អ្នក។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែលការចុះឈ្មោះចូលរៀនត្រូវបានសម្រេច សូមចូលមើល ការចុះឈ្មោះចូលរៀន។

## តើខ្ញុំអាចចុះឈ្មោះកូនរបស់ខ្ញុំក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលាបឋមសិក្សាដោយរបៀបណា?

នេះគឺជារបៀបចុះឈ្មោះកូនរបស់អ្នកឲ្យចូលរៀនក្នុងឆ្នាំដំបូងនៃសាលាបឋមសិក្សា៖

1. **ស្វែងរកសាលារៀនក្នុងតំបន់របស់អ្នក**
   ចូលទៅកាន់ www.findmyschool.vic.gov.au ដើម្បីស្វែងរកសាលាបឋមសិក្សារដ្ឋក្នុងតំបន់របស់អ្នក ឬសាលារៀនទាំងឡាយដែលនៅក្បែរ។

2. **ទាក់ទងសាលារៀននោះ**
   ទាក់ទងសាលាបឋមសិក្សានោះដើម្បីកក់ពេលទៅមើលសាលា ប្រសិនបើចង់។ ពិនិត្យថាតើសាលារៀននឹងប្រើប្រាស់បែបបទចុះឈ្មោះចូលរៀនតាមអនឡាញ (VicStudents) ឬតាមទម្រង់បែបបទជាក្រដាស។ ព័ត៌មាននេះនឹងមានតាមរយៈគេហទំព័ររបស់សាលារៀន។

3. **ទាញយកកញ្ចប់ព័ត៌មាន**
   ទាញយកកញ្ចប់ព័ត៌មានការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) ពី ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។ កញ្ចប់នេះនឹងមាននៅថ្ងៃព្រហស្បតិ៍ ទី 2 ខែមេសា ឆ្នាំ 2026។

4. **ដាក់ពាក្យសុំចុះឈ្មោះចូលរៀនរបស់អ្នកចូល**
   ដាក់ចូលពាក្យសុំចុះឈ្មោះចូលរៀន**ត្រឹមថ្ងៃសុក្រ ទី 31 ខែកក្កដា ឆ្នាំ 2026** តាមអនឡាញ (VicStudents) ឬក៏ប្រើប្រាស់ទម្រង់បែបបទក្រដាសដោយផ្អែកលើបែបបទរបស់សាលារៀន ដែលបានពិពណ៌នានៅលើគេហទំព័ររបស់ពួកគេ។

5. **ទទួលលទ្ធផល**
   អ្នកនឹងត្រូវបានជូនដំណឹងអំពីលទ្ធផលនៃការដាក់ពាក្យសុំចុះឈ្មោះចូលរៀនរបស់អ្នក**រវាងថ្ងៃចន្ទ ទី 3 ខែសីហា និងថ្ងៃសុក្រ ទី 14 ខែសីហា ឆ្នាំ 2026**។ ប្រសិនបើអ្នកទទួលបានការផ្តល់ជូនកន្លែងចូលរៀន អ្នកគួរតែទទួលយកការផ្តល់ជូននោះត្រឹម**ថ្ងៃសុក្រ ទី 28 ខែសីហា ឆ្នាំ 2026**។

6. **ត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរអន្តរកាលទៅសាលារៀនរបស់កូនអ្នក**
   ចូលរួមក្នុងវគ្គអន្តរកាលសិស្សក្នុងអំឡុងត្រីមាសទី 4 ឆ្នាំ 2026។ កូនរបស់អ្នកនឹងចាប់ផ្តើមចូលរៀនថ្នាក់មូលដ្ឋាន ចាប់ពី**ថ្ងៃព្រហស្បតិ៍ ទី 28 ខែមករា ឆ្នាំ 2027**។

## តើខ្ញុំស្វែងរកសាលារៀនក្នុងតំបន់របស់ខ្ញុំដោយរបៀបណា?

អ្នកអាចស្វែងរកសាលារៀនក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ Find My School (ស្វែងរកសាលារៀនរបស់ខ្ញុំ) ដោយធ្វើតាមជំហានខាងក្រោម៖

1. បញ្ចូល www.findmyschool.vic.gov.au ទៅក្នុងកម្មវិធីរុករករបស់អ្នក។
2. វាយបញ្ចូលអាសយដ្ឋានរស់នៅអចិន្ត្រៃយ៍របស់អ្នកនៅក្រោមពាក្យ ‘Enter your address to get started (បញ្ចូលអាសយដ្ឋានរបស់អ្នកដើម្បីចាប់ផ្តើម)’។
3. ជ្រើសរើសឆ្នាំ 2027 នៅក្រោម “Enrolment year (ឆ្នាំចុះឈ្មោះចូលរៀន)”។ **តំបន់សាលាសម្រាប់ឆ្នាំ 2027** នឹងមាននៅ**ថ្ងៃព្រហស្បតិ៍ ទី 2 ខែមេសា ឆ្នាំ 2026។**
4. ជ្រើសរើសបឋមសិក្សានៅក្រោមពាក្យ 'ប្រភេទសាលារៀន'។

បន្ទាប់មក ផែនទីនឹងបង្ហាញអាសយដ្ឋានរបស់អ្នក សាលារៀនក្នុងតំបន់របស់អ្នក ហើយនៅផ្នែកខាងឆ្វេងនឹងបង្ហាញពីព័ត៌មានទំនាក់ទំនងលម្អិតរបស់សាលារៀន។ ប្រសិនបើអ្នករំកិលចុះក្រោម វាក៏នឹងបង្ហាញអ្នកនូវសាលារៀនចំនួនប្រាំដែលនៅក្បែរអាសយដ្ឋានរបស់អ្នកបំផុត។ អ្នកក៏អាចស្វែងរកតាមឈ្មោះសាលារៀនផងដែរនៅក្រោមពាក្យ 'Search for school (ស្វែងរកសាលារៀន)'។

## ចុះប្រសិនបើពាក្យសុំចុះឈ្មោះរបស់ខ្ញុំមិនទទួលបានជោគជ័យ?

ប្រសិនបើពាក្យសុំរបស់អ្នកមិនទទួលបានជោគជ័យ អ្នកអាច៖

- **ដាក់ពាក្យ**ទៅសាលារៀនផ្សេងមួយទៀត។ កូនរបស់អ្នកត្រូវបានធានាឱ្យចូលរៀននៅសាលារៀនក្នុងតំបន់របស់ពួកគេ។ ចូលមើល **Find my School** ដើម្បីកំណត់ទីតាំងសាលាក្នុងតំបន់របស់កូនអ្នក។
- ការតវ៉ា ឬប្តឹងជំទាស់លើការសម្រេចចិត្ត។ ទំព័រ ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) មានព័ត៌មានអំពីដំណើរការប្តឹងជំទាស់លើលទ្ធផលនៃការដាក់ពាក្យសុំចុះឈ្មោះចូលរៀន។

## តើមានអ្វីកើតឡើងប្រសិនបើខ្ញុំខកខានចំពោះពេលវេលាចុះឈ្មោះចូលរៀន?

អ្នកអាចដាក់ពាក្យចុះឈ្មោះកូនរបស់អ្នកចូលរៀនថ្នាក់មូលដ្ឋានសម្រាប់ឆ្នាំសិក្សា 2027 នៅពេលណាក៏បាន ចាប់ពី**ថ្ងៃចន្ទ ទី 20 ខែមេសា ឆ្នាំ 2026**។

ទោះបីអ្នកត្រូវបានស្នើសុំឱ្យដាក់ពាក្យសុំចុះឈ្មោះចូលរៀន**ត្រឹមថ្ងៃសុក្រ ទី 31 ខែកក្កដា ឆ្នាំ 2026** ការដាក់ពាក្យសុំយឺតយ៉ាវនឹងនៅតែត្រូវបានទទួលយកពីគ្រួសារនានាដែលអាចខកខានពេលវេលាចុះឈ្មោះ ផ្លាស់ទីលំនៅអចិន្ត្រៃយ៍ ឬទើបតែមកដល់រដ្ឋវិចថូរៀ។

ពាក្យសុំចុះឈ្មោះចូលរៀនដែល**ដាក់ចូលក្រោយថ្ងៃទី 31 ខែកក្កដា ឆ្នាំ 2026** នឹងត្រូវបានចាត់ចែងដោយសាលាបឋមសិក្សានោះ**នៅពេលទទួលបាន** ស្របតាមគោលនយោបាយចុះឈ្មោះចូលរៀនរបស់ក្រសួង។

## តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សានៅឯណា?

អ្នកអាចសួរសាលាបឋមសិក្សាក្នុងតំបន់របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន។

ចាប់ពី**ថ្ងៃចន្ទ ទី 20 ខែមេសា ឆ្នាំ 2026** អ្នកក៏អាចស្វែងរកកញ្ចប់ព័ត៌មានអំពីបែបបទចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន នៅលើទំព័រចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម)។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបកប្រែកញ្ចប់ព័ត៌មាន សូមនិយាយទៅកាន់សាលាបឋមសិក្សាក្នុងតំបន់របស់អ្នកដើម្បីសុំជំនួយ។

## តើខ្ញុំត្រូវទាក់ទងអ្នកណាដើម្បីសុំជំនួយ?

អ្នកសម្របសម្រួលការផ្ទេរអន្តរកាល មន្ត្រីចុះឈ្មោះ ឬនាយកសាលាបឋមសិក្សាដែលអ្នកចង់ដាក់ពាក្យសុំ អាចជួយអ្នកដើម្បីឆ្លើយតបនឹងសំណួរណាមួយដែលអ្នកចង់សួរ អំពីដំណើរការចុះឈ្មោះ។

## តំណភ្ជាប់ដែលមានប្រយោជន៍

សូមមើលតំណភ្ជាប់ដែលមានប្រយោជន៍មួយចំនួនខាងក្រោម ដែលអាចមានប្រយោជន៍សម្រាប់អ្នក នៅពេលកូនរបស់អ្នកចាប់ផ្តើមសាលាបឋមសិក្សា៖

Find my School (ស្វែងរកសាលារៀនរបស់ខ្ញុំ) - findmyschool.vic.gov.au

ព័ត៌មានអំពីតំបន់សាលារៀន –vic.gov.au/school-zones

ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) –vic.gov.au/enrolling-foundation-prep

ការចុះឈ្មោះចូលរៀននៅសាលា – vic.gov.au/how-choose-school-and-enrol

ពិការភាព និងការអប់រំមានលក្ខណៈរួមបញ្ចូល – vic.gov.au/disability-and-inclusive-education

ទំនាក់ទំនងការិយាល័យប្រចាំតំបន់ – vic.gov.au/office-locations-department-education

# កាលវិភាគសម្រាប់ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) ឆ្នាំ 2027

| កាលបរិច្ឆេទ ឆ្នាំ 2026 | តើឪពុកម្តាយ/អ្នកថែទាំត្រូវធ្វើអ្វីខ្លះ? |
|---|---|
| **ត្រីមាសទី 1** | **ថ្ងៃអង្គារ ទី 27 ខែមករា (សិស្សចាប់ផ្តើមចូលរៀនថ្ងៃទី 28 ខែមករា) – ថ្ងៃព្រហស្បតិ៍ ទី 2 ខែមេសា ឆ្នាំ 2026** |
| **ត្រីមាសទី 1 និងទី 2 ឆ្នាំ 2026** | • **ចូលរួមដំណើរទៅមើលសាលា**ដែលរៀបចំដោយសាលាបឋមសិក្សានានា *(តាមការស្ម័គ្រចិត្ត)*។ |
| **ត្រឹមថ្ងៃព្រហស្បតិ៍ ទី 2 ខែមេសា ឆ្នាំ 2026** | • តំបន់សាលារៀនសម្រាប់ឆ្នាំសិក្សា 2027 អាចរកបាន។ អ្នកអាចស្វែងរកសាលារៀនក្នុងតំបន់របស់អ្នកនៅតាមគេហទំព័រ www.findmyschool.vic.gov.au។ |
| **ត្រីមាសទី 2** | **ថ្ងៃចន្ទ ទី 20 ខែមេសា - ថ្ងៃសុក្រ ទី 26 ខែមិថុនា ឆ្នាំ 2026** |
| **ចាប់ពីថ្ងៃចន្ទ ទី 20 ខែមេសា ឆ្នាំ 2026** | • ចាប់ពីដើមត្រីមាសទី 2 **សូមបំពេញ និងដាក់ពាក្យសុំរបស់កូនអ្នក** - ទាំងតាមអនឡាញ ឬក៏ប្រើប្រាស់ទម្រង់បែបបទដាក់ពាក្យសុំនៅក្នុងកញ្ចប់ព័ត៌មានចុះឈ្មោះចូលរៀន អាស្រ័យលើអ្វីដែលសាលារៀនរបស់អ្នកណែនាំ។<br>• អ្នកអាច**ទាញយកកញ្ចប់ព័ត៌មានចុះឈ្មោះចូលរៀន**ពី ការចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋាន (ថ្នាក់ត្រៀម) សម្រាប់ព័ត៌មានលម្អិតបន្ថែម។ |
| **ត្រីមាសទី 3** | **ថ្ងៃចន្ទ ទី 13 ខែកក្កដា ដល់ថ្ងៃសុក្រ ទី 18 ខែកញ្ញា ឆ្នាំ 2026** |
| **ត្រឹមថ្ងៃសុក្រ ទី 31 ខែកក្កដា ឆ្នាំ 2026** | • **ដាក់ពាក្យសុំដែលបានបំពេញរបស់អ្នក**ចូលទៅសាលាបឋមសិក្សាត្រឹមកាលបរិច្ឆេទនេះ។ |
| **រវាងថ្ងៃចន្ទ ទី 3 ខែសីហា ដល់ថ្ងៃសុក្រ ទី 14 ខែសីហា ឆ្នាំ 2026** | • **សាលាបឋមសិក្សានឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរ** អំពីលទ្ធផលនៃការចុះឈ្មោះចូលរៀន**ក្នុងអំឡុងពេលនេះ។**<br>• ប្រសិនបើពាក្យសុំរបស់អ្នកមិនទទួលបានជោគជ័យទេ អ្នកអាចដាក់ពាក្យប្តឹងជំទាស់ជាមួយសាលាបឋមសិក្សានោះបាន។ |
| **ត្រឹមថ្ងៃសុក្រ ទី 28 ខែសីហា ឆ្នាំ 2026** | • **សូមបញ្ជាក់ការទទួលយកកន្លែងចូលរៀនរបស់កូនអ្នក**ដោយបំពេញទម្រង់បែបបទចុះឈ្មោះចូលរៀនដែលបានផ្តល់ជូន ជាមួយនឹងការផ្តល់ជូនការចុះឈ្មោះចូលរៀន។<br>• ប្រសិនបើអ្នកមានបំណងប្តឹងជំទាស់ សូមដាក់ពាក្យប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅសាលាបឋមសិក្សារបស់អ្នកត្រឹមថ្ងៃសុក្រ ទី 28 ខែសីហា។ |
| **ត្រឹមថ្ងៃសុក្រ ទី 11 ខែកញ្ញា ឆ្នាំ 2026** | • សាលាបឋមសិក្សានឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរអំពីលទ្ធផលនៃការប្តឹងជំទាស់។ |
| **ត្រឹមថ្ងៃសុក្រ ទី 18 ខែកញ្ញា ឆ្នាំ 2026** | • ប្រសិនបើអ្នកបានប្តឹងជំទាស់ទៅសាលាបឋមសិក្សារបស់អ្នកដោយមិនបានជោគជ័យ អ្នកអាចដាក់ពាក្យប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរទៅកាន់នាយកតំបន់ដែលពាក់ព័ន្ធ។ |
| **ត្រីមាសទី 4** | **ថ្ងៃចន្ទ ទី 5 ខែតុលា – ថ្ងៃសុក្រ ទី 18 ខែធ្នូ ឆ្នាំ 2026** |
| **ត្រីមាសទី 4 ឆ្នាំ 2026** | • ចូលរួមវគ្គអន្តរកាលដែលរៀបចំដោយសាលាបឋមសិក្សា។ |
| **ត្រឹមថ្ងៃសុក្រ ទី 6 ខែវិច្ឆិកា ឆ្នាំ 2026** | • ប្រសិនបើអ្នកបានដាក់ពាក្យប្តឹងជំទាស់ជាមួយនាយកតំបន់ តំបន់នោះនឹងជូនដំណឹងដល់អ្នកជាលាយលក្ខណ៍អក្សរអំពីលទ្ធផលត្រឹមថ្ងៃកំណត់នេះ។ នេះអនុវត្តចំពោះតែការប្តឹងជំទាស់ដែលទទួលបានមុនថ្ងៃផុតកំណត់គឺថ្ងៃសុក្រ ទី 18 ខែកញ្ញាប៉ុណ្ណោះ។ |